វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រុមប្រឹក្សារដ្ឋមន្ត្រី
សារាចរ/០១ ស.រ/១៨ មករា ១៩៩០/

ស្តីពីការគ្រប់គ្រងគេហដ្ឋាន ដីធ្លី ដែលជួល អោយអង្គការអន្តរជាតិ-ក្រុមហ៊ុន ឬជនបរទេស

ក្នុងទិសពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយបណ្តាប្រទេសសង្គមនិយមជាបងប្អូន និង អង្គការអន្តរជាតិនានា ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច អោយមានប្រសិទ្ធភាព និងបង្កលក្ខណសម្បត្តិអោយក្រុមហ៊ុន ឬភ្ញៀវបរទេសចូលមកធ្វើអាជីវកម្ម ផលិតកម្ម ដើម្បីរួមចំណែកស្តារសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេសជាតិ បញ្ហាដោះស្រាយគេហដ្ឋាន ដីធ្លីសំរាប់បណ្តាអង្គការអន្តរជាតិ ក្រុមហ៊ុន ឬ ភ្ញៀវបរទេសនៅទីក្រុងភ្នំពេញ និងតាមទីរួមខេត្តនានា គឺជាការចាំបាច់សំខាន់មួយផ្នែកដែរ។

ផ្អែកតាមសភាពការណ៍នេះ ក្រុមប្រឹក្សារដ្ឋមន្ត្រី កំណត់នូវវិធានការចាំបាច់ចំពោះមុខដូចខាងក្រោមនេះ:

១- ជនបរទេសដែលបានទទួលការអនុញ្ញាតអោយស្នាក់នៅក្នុងរដ្ឋកម្ពុជា មានសិទ្ធិជួលគេហដ្ឋាន ដីធ្លី បាន។

២- ក្រសួងការបរទេស ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវរួមគ្នាទទួលខុសត្រូវក្នុងការរៀបចំគេហដ្ឋាន ដីធ្លីដល់បណ្តាអង្គការអន្តរជាតិ ក្រុមហ៊ុន ឬភ្ញៀវបរទេសដែលធ្វើសកម្មភាពនៅតាមខេត្ត-ក្រុងនីមួយៗ ដោយត្រូវយកចិត្តទុកដាក់សំខាន់បំផុតដល់បញ្ហាថែរក្សា ការពារសន្តិសុខ ជូនភ្ញៀវអោយបានល្អ។

៣- អនុញ្ញាតអោយពលរដ្ឋកម្ពុជា អាចជួលគេហដ្ឋាន ដីធ្លីជាកម្មសិទ្ធិរបស់ខ្លួនដល់អង្គការអន្តរជាតិ ក្រុមហ៊ុន ឬភ្ញៀវបរទេសណា ដែលមានការអនុញ្ញាតអោយស្នាក់អាស្រ័យនៅ និងធ្វើបេសកកម្មនៅក្នុងរដ្ឋកម្ពុជាពីក្រសួងការបទេស។ ការជួលគេហដ្ឋាន ដីធ្លីនេះ ត្រូវមានការអនុញ្ញាតពីគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ដោយមានយោបល់ឯកភាពពីក្រសួងមហាផ្ទៃ និងក្រសួងការបរទេស។ ពលរដ្ឋកម្ពុជាដែលមានគេហដ្ឋាន ដីធ្លីជាកម្មសិទ្ធិ ហើយមានបំណងចង់ជួលអោយជនបរទេស ចាំបាច់ត្រូវមកចុះឈ្មោះផ្តល់ពតិមានដល់គណៈកម្មា-ធិការប្រជាជនខេត្ត-ក្រុង។

៤- ក្នុងការកំណត់ថ្លៃឈ្នួលគេហដ្ឋាន ដីធ្លីជាមូលដ្ឋានសំរាប់ជនបរទេស គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង រៀបចំបទដ្ឋានមួយនៅតាមភូមិសាស្ត្រ និងប្រភេទគេហដ្ឋានដីធ្លីនីមួយៗ ។ ផ្អែកតាមថ្លៃឈ្នួលជាមូលដ្ឋាននេះ ម្ចាស់គេហដ្ឋាន ដីធ្លីនឹងពិភាក្សាលំអិតជាក់ស្តែងថែមទៀត អោយឯកភាពជាមួយអ្នកទទួល ជួល។

៥- ម្ចាស់កម្មសិទ្ធគេហដ្ឋាន ដីធ្លីដែលជួលអោយជនបរទេស ត្រូវមានកាតព្វកិច្ចដូចតទៅ :

- ចូលរួមក្នុងចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម។
- ត្រូវបង់ពន្ធប៉ាតង់ និងពន្ធអាជីវកម្មចំពោះចំណូលដែលបានមកពីការជួលគេហដ្ឋាន ដីធ្លី តាមបណ្តា ក្រឹត្យ-ច្បាប់ដែលមានចែង។
- ត្រូវបើកគណនីជាប្រាក់រៀលនៅធនាគារ ហើយត្រូវផ្ទេរថ្លៃឈ្នួលគេហដ្ឋាន ដីធ្លី ពីរូបិយប័ណ្ណបរទេស មកជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ ដែលប្រកាសផ្សាយដោយធនាគារជាតិកម្ពុជា បញ្ចូលទៅក្នុងគណនី ខាងលើ។
- កិច្ចសន្យាជាលាយលក្ខណ៍អក្សរ ជួលគេហដ្ឋាន ដីធ្លី អោយជនបរទេស ត្រូវបានការឯកភាពពីគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង។

៦- អ្នកជួលគេហដ្ឋាន ដីធ្លី មានកាតព្វកិច្ចគោរពតាមកិច្ចសន្យាដែលបានឯកភាព ចុះហត្ថលេខាជាមួយម្ចាស់គេហដ្ឋាន ដីធ្លី ។

គ្រប់ក្រសួង ស្ថាប័ន គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ផ្អែកលើខ្លឹមសារនៃសារាចរនេះ ត្រូវធ្វើការ ផ្សព្វផ្សាយអោយបានទូលំទូលាយ និងចាត់តាំងអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ។